ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សារលិខិតជូនពរ

សូមគោរពជូន
**សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត ហេង សំរិន**
**ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

*សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់*

ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រសើរថ្លៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយនៃទិវាខួបកំណើតគម្រប់ ៨៦ឆ្នាំ ឈានចូល ៨៧ឆ្នាំ របស់ **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត** យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវក្តីអំណរសាទរយ៉ាងក្រៃលែង និងសូមគោរពជូនពរនូវសព្ទសាធុការពរជ័យ មហាប្រសើរគ្រប់ប្រការជូនចំពោះ **សម្តេចប្រធានរដ្ឋសភា**។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវកតញ្ញុតា និងកតវេទិតាយ៉ាងស្មោះស្ម័គ្រជាទីបំផុត ចំពោះ **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត** ដែលជានិច្ចកាល **សម្តេច** តែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងបទពិសោធន៍ដ៏ឈ្លៀសវៃ ដើម្បីដឹកនាំស្ថាប័នរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចូលរួមកសាងនូវសមិទ្ធផលសង្គមទទួលជោគជ័យគួរជាទីមោទនៈជាបន្តបន្ទាប់។ ជាមួយគ្នានេះ ស្ថាប័នរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចប្រធាន** នាពេលកន្លងមក បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដើម្បីរួមចំណែកក្នុងការធានាដល់សន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌ប្រកបដោយចីរភាព ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

ឆ្លៀតក្នុងឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក បុណ្យបារមីទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា និងទេវតាឆ្នាំថ្មីព្រះនាមគោរគទេវី សូមប្រោសប្រទានជូន **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត សម្តេចធម្មវិសុទ្ធវង្សា** បុត្រា បុត្រី និងចៅប្រុស ចៅស្រី មានសុខភាពល្អបរិបូណ៌ និងទទួលបាននូវពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ៕

ថ្ងៃសៅរ៍ ២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២០
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**
**នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវិថីអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh